# ឯកសារទស្សនទាន
# កម្មវិធីបើកសម្ពោធគម្រោង
# ស្តីពីការពង្រឹងសង្គមស៊ីវិលសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
# ប្រកបដោយចីរភាពនៅកម្ពុជា
# ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ

## ១. សេចក្តីសង្ខេបរបស់គម្រោង

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) កំពុងអនុវត្តគម្រោងមួយស្តីពី "**ការពង្រឹងសង្គមស៊ីវិលសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយចីរភាពនៅកម្ពុជា**"។ ថវិកាសម្រាប់គម្រោងនេះមានចំនួន ១,៥លានអឺរ៉ូ ដែលជាការផ្តល់ហិរញ្ញប្បទានរួមគ្នាដោយសហភាពអឺរ៉ុប (EU) និងអង្គការ Bread for the World (BfdW) សម្រាប់រយៈពេល ៤២ខែ ដោយចាប់ផ្តើមពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ ទៅដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០។

ដោយមានបំណងលើកកម្ពស់បរិយាកាសប្រកបដោយអំណោយផលសម្រាប់សង្គមស៊ីវិលក្នុងប្រទេសកម្ពុជា ក៏ដូចជាដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួនឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាពក្នុងប្រទេស អង្គការ គ.ស.ក បានបង្កើតគម្រោងនេះឡើងដោយយកចិត្តទុកដាក់តាមរយៈការពិភាក្សាយ៉ាងទូលំទូលាយ និងរួមបញ្ចូលបទអន្តរាគមតាមបែបនវានុវត្តន៍ប្រសើរបំផុតតាមដែលអាចធ្វើទៅបាន ដើម្បីសម្រេចគោលបំណងរបស់គម្រោងនេះឲ្យបានដល់កម្រិតអតិបរមា។

គោលបំណងរួមរបស់គម្រោងនេះត្រូវបានបែងចែងជាពីរ ១). ពង្រឹងប្រសិទ្ធភាព និងឥទ្ធិពលរបស់អង្គការសង្គមស៊ីវិល និង ២). លើកកម្ពស់បរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល។ នៅក្នុងកម្រិតពិស្តារជាងនេះទៀត គម្រោងនេះមានគោលបំណងជាក់លាក់ចំនួនបីគឺ៖ ១). បង្កើនសមត្ថភាពរបស់អង្គការសង្គមស៊ីវិលក្នុងការឆ្លើយតបប្រកបដោយនវានុវត្តន៍ទៅនឹងបញ្ហាប្រឈមនៃការអភិវឌ្ឍ ២). លើកកម្ពស់ភាពជាដៃគូពហុភាគីពាក់ព័ន្ធក្នុងការបង្កើតគោលនយោបាយ និងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាពនៅគ្រប់កម្រិត និង ៣). លើកកម្ពស់ការចូលរួមប្រកប

ដោយភាពសកម្មរបស់សមាជិកអង្គការ គ.ស.ក និងសេវាកម្មប្រកបដោយនវានុវត្តន៍របស់លេខាធិការដ្ឋាននៃអង្គការ គ.ស.ក។

សូមមើលព័ត៌មានលម្អិតរបស់គម្រោងនៅក្នុងខិត្តប័ណ្ណគម្រោងដែលត្រូវបានភ្ជាប់មកជាមួយ។

## ២. សេក្តីសង្ខេបកម្មវិធីសម្ពោធគម្រោង

កម្មវិធីសម្ពោធគម្រោងនឹងមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធ ១២០នាក់មកពីស្ថាប័ន និងវិស័យផ្សេងៗ។ អ្នកទាំងនេះអញ្ជើញមកពី ស្ថាប័នរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងប្រព័ន្ធផ្សព្វផ្សាយ។

កម្មវិធីនេះនឹងត្រូវបានរៀបចំធ្វើឡើងនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។ ជាទូទៅ កម្មវិធីបើកសម្ពោធគម្រោងនេះ មានគោលបំណងបី៖

- ដើម្បីបើកសម្ពោធជាផ្លូវការ និងលើកកម្ពស់ទស្សនីយភាពរបស់គម្រោង។
- ដើម្បីណែនាំបទអន្តរាគមន៍របស់គម្រោងទៅកាន់ភាគីពាក់ព័ន្ធសំខាន់ៗ។
- ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងការប្តេជ្ញាចិត្តរបស់ភាគីពាក់ព័ន្ធសំខាន់ៗឆ្ពោះទៅរកការសម្រេចបានគោលបំណងរបស់គម្រោង។

ក្រៅពីពិធីបើកសម្ពោធនេះ កម្មវិធីនេះក៏នឹងរួមបញ្ចូលផងដែរនូវរបៀបវារៈចំនួនពីរ ដែលរួមមាន ១). កិច្ចសន្ទនាពហុភាគីស្តីពីភាពជាដៃគូប្រកបដោយបរិយាប័ន្នសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និង ២). ការពិភាក្សាជាក្រុមស្តីពីទម្រង់ និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការសម្រាប់គម្រោងនេះ។

## ៣. របៀបវារៈ

| ម៉ោង | ប្រធានបទពិភាក្សា | វាគ្មិន និងអ្នកសម្របសម្រួល |
|---|---|---|
| ០៨:៣០ - ០៩:០០ | ចុះឈ្មោះ និងបង្កើតទំនាក់ទំនង | អង្គការ គ.ស.ក |
| ០៩:០០ - ០៩:១៥ | គោរពភ្លេងជាតិ និងការណែនាំអំពីគោលបំណងរបស់គម្រោង និងរបៀបវារៈ | **កញ្ញា កៅ ពៅលក្ខិណា** ពិធីការនីកម្មវិធី |
| ០៩:១៥ - ០៩:៣០ | បទបង្ហាញស្តីពីគម្រោង | **លោកស្រី អែល សុជាវី** ប្រធានកម្មវិធី |

| | | |
|---|---|---|
| | | អង្គការ គ.ស.ក |
| ០៩:៣០ - ០៩:៤៥ | សុន្ទរកថាស្វាគមន៍ដោយ អង្គការ គ.ស.ក | **លោកស្រី ចាន់ ណារី** អនុប្រធានគណៈកម្មាធិការប្រតិបត្តិ អង្គការ គ.ស.ក |
| ០៩:៤៥ - ១០:០០ | សុន្ទរកថាស្វាគមន៍ដោយអ្នកតំណាងសហភាពអឺរ៉ុប | **ឯកឧត្តម George EDGAR** ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំប្រទេសកម្ពុជា |
| ១០:០០ - ១០:១៥ | សុន្ទរកថាបើកសម្ពោធជាផ្លូវការដោយ ឯកឧត្តម តំណាងមកពីក្រសួងមហាផ្ទៃ | **ឯកឧត្តម ង៉ាន់ ចំរើន** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានប្រតិបត្តិ NCDDS |
| ១០:១៥ - ១០:៤៥ | ថតរូបជាក្រុម សម្រាកពេលព្រឹក និងសន្ទនាជាមួយប្រព័ន្ធផ្សព្វផ្សាយ | ទាំងអស់គ្នា, ក្រុមទំនាក់ទំនងអង្គការ គ.ស.ក |
| ១០:៤៥ - ១២:០០ | កិច្ចសន្ទនារបស់ពហុភាគីពាក់ព័ន្ធស្តីពីភាពជាដៃគូប្រកបដោយបរិយាប័ន្នដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព | អ្នកសម្របសម្រួលៈ **លោក ម៉ម សម្បត្តិ** នាយកប្រតិបត្តិអង្គការ DPA<br>វាគ្មិនៈ<br>- **ឯកឧត្តម ង៉ាន់ ចំរើន** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានប្រតិបត្តិ NCDDS<br>- លោកស្រី Fiona Ramsey ប្រធានផ្នែកកិច្ចសហប្រតិបត្តិការសហភាពអឺរ៉ុប<br>- លោក**បណ្ឌិត តាន់ មុនីវណ្ណ** អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា និងជាអគ្គនាយករងនៃក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប<br>- **លោក សៀង សារឿន** នាយកប្រតិបត្តិអង្គការ គ.ស.ក |
| ១២:០០ - ១៣:៣០ | **អាហារថ្ងៃត្រង់** | ទាំងអស់គ្នា |
| ១៣:៣០ - ១៥:០០ | ការពិភាក្សាជាក្រុមស្តីពីទម្រង់ និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការ | អ្នកសម្របសម្រួលៈ **លោក មី ណាក់** អ្នកគ្រប់គ្រង សមាសភាគ CAN នៃ អង្គការ គ.ស.ក |

| | | |
|---|---|---|
| | និងទំនាក់ទំនងសម្រាប់គម្រោងនេះ | |
| ១៥:០០ - ១៥:៣០ | សម្រាកពេលរសៀល | ទាំងអស់គ្នា |
| ១៥:៣០ - ១៥:៤៥ | សេចក្តីសន្និដ្ឋាន និងសកម្មភាពបន្តសម្រាប់ពេលអនាគត | **លោក ជេន សុជឿន** អ្នកគ្រប់គ្រងផ្នែកស្រាវជ្រាវ និងអភិវឌ្ឍសមាជិកភាពរបស់អង្គការ គ.ស.ក |
| ១៥:៤៥ - ១៦:០០ | សុន្ទរកថាបិទ | **លោក សឿង សារឿន** នាយកប្រតិបត្តិអង្គការ គ.ស.ក |

**សំគាល់:** អង្គការគ.ស.ក រក្សាសិទ្ធិក្នុងការកែប្រែរបៀបវារៈ អាស្រ័យដោយពេលវេលា និងវាគ្មិន។ រាល់ឯកសារពាក់ព័ន្ធ រូបថត និងសកម្មភាពសំខាន់ៗ នឹងត្រូវចុះផ្សាយនៅ លើគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់អង្គការគ.ស.ក។

សម្រាប់ឯកសាររក្សាទុកសូមទាញយកចេញពី:

http://www.ccc-cambodia.org/resources/events-archive.html

www.facebook.com/CCCsince1990

www.youtube.com/CCCambodia